# ក្រសួងអប់រំ យុវជន និងកីឡា

# សិក្ខាសាលាចែករំលែកឧត្តមានុវត្តន៍នៃការអនុវត្ត កញ្ចប់សម្ភារៈអំណាននិងគណិតវិទ្យាថ្នាក់ដំបូង

## បទបង្ហាញស្តីពី

## យុទ្ធសាស្ត្រនៃការអនុវត្តកញ្ចប់សម្ភារៈអំណាននិងគណិតវិទ្យាថ្នាក់ដំបូង

បង្ហាញដោយៈ ឯកឧត្តមបណ្ឌិត ចាន់ សុភា ប្រធាននាយកដ្ឋានបឋមសិក្សា

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២

# មាតិកា

១. យុទ្ធសាស្ត្រអនុវត្ត

២. ផែនទី និងគម្រូវការថវិកា

៣. អត្រាឧបត្ថម្ភសម្រាប់ដំណើរការបំប៉ន និងសិក្ខាសាលា

# ១. យុទ្ធសាស្រ្តអនុវត្ត

សេចក្ដីណែនាំលេខ ១៦ ជាមួយយុទ្ធសាស្ត្រអនុវត្តកញ្ចប់សម្ភារៈអំណាននិងគណិតវិទ្យាថ្នាក់ដំបូង.pdf

# ១.១. ចក្ខុវិស័យ

សិស្សបឋមសិក្សាទាំងអស់មានសមត្ថភាពមូលដ្ឋាន
គ្រប់គ្រាន់លើផ្នែកអាន-សរសេរភាសាខ្មែរ និងគណិតវិទ្យា
នៅកម្រិតថ្នាក់ដំបូង។

# ១.២. ទស្សនៈ

■ កញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ដែលបានបង្កើតឡើង ដើម្បីឱ្យគ្រប់អ្នកពាក់ព័ន្ធ ជាពិសេសគ្រូបង្រៀនថ្នាក់ទី១ និងទី២ មានកញ្ចប់សម្ភារៈអប្បបរមាមួយ ដែលអាចយកទៅប្រើប្រាស់ និងពង្រីកការអនុវត្តនៅទូទាំងប្រទេស ក្នុងន័យលើកកម្ពស់គុណភាពអប់រំ តាមរយៈការបង្កើនលទ្ធផលសិក្សារបស់សិស្សនៅបឋមសិក្សា ពោលគឺកុមារកម្ពុជាចេះអាន សរសេរ និងគិតលេខទាំងអស់គ្នា។

■ មន្ត្រីអប់រំផ្នែកបឋមសិក្សា ជាពិសេសគ្រូបង្រៀនកម្រិតថ្នាក់ដំបូង មានសមត្ថភាពគ្រប់គ្រាន់លើចំណេះដឹងវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ បច្ចេកវិទ្យាព័ត៌មាន និងភាសាបរទេស ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ចេះប្រើប្រាស់វិធីសាស្ត្របង្រៀនដែលសម្បូរបែប ប្រកបដោយភាពច្នៃប្រឌិត ចេះគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព និងឈានទៅលើកកម្ពស់គុណភាពអប់រំនៅកម្រិតបឋមសិក្សា។

# ១.៣. បេសកកម្ម

- បង្កើនសមត្ថភាពជាប្រចាំជូនដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ជាពិសេសសមត្ថភាពលើវិធីសាស្ត្របង្រៀន ការផលិតសម្ភារៈបង្រៀននិងរៀន និងការណែនាំអនុវត្ត
- ធ្វើការបណ្តុះបណ្តាលបន្តដល់គ្រូឧទ្ទេសនៅសាលាគរុកោសល្យ មន្ត្រីជំនាញរបស់មន្ទីរ គ្រូបង្រៀនល្អ ស្តីពីការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង
- ពង្រឹងប្រព័ន្ធនៃការអនុវត្ត តាមរយៈការពិនិត្យតាមដាន និងការផ្តល់ប្រឹក្សាគរុកោសល្យ
- សហការជាមួយអង្គភាពពាក់ព័ន្ធ អង្គការដៃគូអប់រំ ដើម្បីជំរុញការអភិវឌ្ឍនិងអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង
- ជំរុញនិងលើកកម្ពស់ការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល សហគមន៍ អាជ្ញាធរដែនដី វិស័យឯកជននិងអ្នកពាក់ព័ន្ធ ក្នុងការតាមដានការសិក្សារបស់កូន និងគាំទ្របន្ថែមតាមតម្រូវការ។

# ១.៤. យុទ្ធសាស្រ្តនៃការអនុវត្ត រយៈពេលខ្លី

| យុទ្ធសាស្រ្តវែង | ការពង្រីកកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង |
| --- | --- |
| សកម្មភាព | បំប៉នគ្រូបង្រៀនថ្នាក់ទី១ និងអ្នកពាក់ព័ន្ធ ស្តីពីការអនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង នៅខេត្តបន្ទាយមានជ័យ ប៉ៃលិន ពោធិ៍សាត់ កោះកុង កំពង់ស្ពឺ ព្រះសីហនុ រតនគិរី មណ្ឌលគិរី កំពង់ឆ្នាំង និងស្រុកកងមាស ខេត្តកំពង់ចាម |
| សកម្មភាព | បំប៉នស្តីពីការអនុវត្តកញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ដំបូងដល់គ្រូបង្រៀនថ្នាក់ទី១ និងអ្នកពាក់ព័ន្ធ នៅខេត្តកំពង់ធំ និងថ្នាក់ទី២ នៅខេត្តក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងឧត្តរមានជ័យ |
| សកម្មភាព | ផ្តល់ប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀនថ្នាក់ទី១ និងទី២ ដោយទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន និងទីប្រឹក្សាគរុកោសល្យជំនាញ នៅខេត្តគោលដៅដែលបានអនុវត្តកន្លងមក |
| សកម្មភាព | បន្តអភិវឌ្ឍកញ្ចប់សម្ភារៈអំណានថ្នាក់ទី៣ និងគណិតវិទ្យាថ្នាក់ទី៣ |

# ១.៥. យុទ្ធសាស្ត្រនៃការអនុវត្ត រយៈពេលមធ្យម

| យុទ្ធសាស្ត្រ៖ | ការពង្រឹងនិងពង្រីកកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង នៅទូទាំងប្រទេស |
|---|---|
| សកម្មភាព | បំប៉នគ្រូបង្រៀនថ្នាក់ទី១ និងអ្នកពាក់ព័ន្ធ ស្តីពីការអនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង នៅខេត្តកំពង់ចាម ត្បូងឃ្មុំ កណ្តាល ព្រៃវែង ស្វាយរៀង តាកែវ បាត់ដំបង និងរាជធានីភ្នំពេញ |
| សកម្មភាព | បំប៉នគ្រូបង្រៀនថ្នាក់ទី២ និងអ្នកពាក់ព័ន្ធ ស្តីពីការអនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង នៅខេត្តបន្ទាយមានជ័យ ប៉ៃលិន ពោធិ៍សាត់ កោះកុង កំពង់ស្ពឺ ព្រះសីហនុ រតនគិរី មណ្ឌលគិរី និងកំពង់ឆ្នាំង |
| សកម្មភាព | បំប៉នស្តីពីការអនុវត្តកញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ដំបូងដល់គ្រូបង្រៀនថ្នាក់ទី១ និងអ្នកពាក់ព័ន្ធ នៅខេត្តកំពត និងកែប និងថ្នាក់ទី២ នៅខេត្តកំពង់ធំ |
| សកម្មភាព | ផ្តល់ប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀនថ្នាក់ទី១ និងទី២ ដោយទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន និងទីប្រឹក្សាគរុកោសល្យជំនាញ នៅខេត្តគោលដៅដែលបានអនុវត្តកន្លងមក |
| សកម្មភាព | អនុវត្តសាកល្បងកញ្ចប់សម្ភារៈអំណានថ្នាក់ទី៣ នៅខេត្តកំពង់ធំ និងគណិតវិទ្យាថ្នាក់ទី៣ នៅខេត្តសៀមរាប |

# ១.៥. យុទ្ធសាស្ត្រនៃការអនុវត្ត រយៈពេលមធ្យម

| យុទ្ធសាស្ត្រ៤ | ការពង្រឹងនិងពង្រីកកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង នៅទូទាំងប្រទេស |
|---|---|
| សកម្មភាព | ពង្រឹងគុណភាពគ្រូឧទ្ទេសដែលមានស្រាប់ ពង្រីកបរិមាណគ្រូឧទ្ទេសគ្រប់កម្រិត ជាពិសេសការបំប៉នគ្រូឧទ្ទេសសាលាគរុកោសល្យឯកទេសអក្សរសាស្ត្រខ្មែរ និងគ្រូបង្រៀនល្អ |
| សកម្មភាព | រៀបចំឱ្យមានការធ្វើវិក្រឹតការគ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ នៅពេលវេលាសមស្រប ឬមហាវិស្សមកាល |
| សកម្មភាព | រៀបចំឱ្យមានការបំប៉នតាមកម្រងសាលារៀន នៅថ្ងៃព្រហស្បតិ៍សប្ដាហ៍ទី៤ នៃខែអំឡុងពេលប្រជុំបច្ចេកទេសទៅតាមតម្រូវការជាក់ស្ដែង |
| សកម្មភាព | ពង្រឹងការធ្វើអធិការកិច្ច និងការពិនិត្យតាមដានពីថ្នាក់ក្រសួង មន្ទីរ អ.យ.ក.រាជធានី ខេត្ត គ្រូឧទ្ទេសសាលាគរុកោសល្យ ការិយាល័យ អ.យ.ក.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| សកម្មភាព | ជំរុញឱ្យបង្កើតសហគមន៍អ្នកសិក្សាវិជ្ជាជីវៈ (PLC) រៀបចំការស្រាវជ្រាវប្រតិបត្តិ (Action Research) និងលើកទឹកចិត្តឱ្យមានការពិភាក្សាផ្លាស់ប្ដូរយោបល់ដោយផ្ទាល់ ឬ អនឡាញ ព្រមទាំងរក្សាទុករាល់ឯកសារដែលពាក់ព័ន្ធ |

# ១.៥. យុទ្ធសាស្ត្រនៃការអនុវត្ត រយៈពេលមធ្យម

| យុទ្ធសាស្ត្ររង | ការពង្រឹងនិងពង្រីកកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង នៅទូទាំងប្រទេស |
|---|---|
| សកម្មភាព | ជំរុញដំណើរការបណ្ណាល័យសម្រាប់សាលារៀនដែលមានបណ្ណាល័យស្រាប់ និងបង្កើតបណ្ណាល័យថ្មី នៅតាមសាលារៀនដែលមិនទាន់មាន |
| សកម្មភាព | ជំរុញនិងលើកកម្ពស់សកម្មភាពអំណានឮ អំណានដៃគូ អំណានចូលរួម និងអំណានបុគ្គល តាមរយៈការសម្របសម្រួលពីគ្រូបង្រៀន និងក្រុមប្រឹក្សាកុមារ |
| សកម្មភាព | លើកទឹកចិត្តមាតាបិតា អ្នកអាណាព្យាបាលឱ្យ ខ្ចី-សង សៀវភៅពីបណ្ណាល័យ និង/ឬ ទិញសៀវភៅអានផ្សេងៗឱ្យកូនអាន ព្រមទាំងចូលរួមអានសៀវភៅជាមួយកូន ឬ ស្តាប់កូនអាននៅផ្ទះ |
| សកម្មភាព | លើកទឹកចិត្តឱ្យមានការបង្កើតនិងដំណើរការបណ្ណាល័យសហគមន៍ និងចូលរួមឧបត្ថម្ភបរិច្ចាគសៀវភៅ និងឯកសារស្រាវជ្រាវផ្សេងៗ ពីសហគមន៍ សប្បុរសជន សិស្សានុសិស្ស អង្គការដៃគូ វិស័យឯកជន... |
| សកម្មភាព | រៀបចំឱ្យមានការប្រឡងប្រណាំងអំណាន សំណេរ និទានរឿង នៅកម្រិតសាលារៀន កម្រងសាលារៀន និងក្រុង ស្រុក ខណ្ឌ |

# ១.៦. យុទ្ធសាស្ត្រនៃការអនុវត្ត រយៈពេលវែង

| យុទ្ធសាស្ត្ររង | ការពង្រឹងនិងពង្រីកកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង នៅទូទាំងប្រទេស |
|---|---|
| សកម្មភាព | រៀបចំការបំប៉នឡើងវិញដល់គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ តាមអនឡាញ |
| សកម្មភាព | ពង្រីកវិសាលភាពការធ្វើវិក្រឹតការគ្រូបង្រៀននៅតាមសាលាគរុកោសល្យ នៅពេលមហាវិស្សមកាល |
| សកម្មភាព | ណែនាំបន្ថែម និងលើកទឹកចិត្តឱ្យគ្រូបង្រៀនធ្វើស្វ័យសិក្សា ស្រាវជ្រាវវិធីសាស្ត្រ និងសម្ភារៈបម្រើឱ្យការបង្រៀននិងរៀនថ្មីៗ |
| សកម្មភាព | ជំរុញការបំប៉នបន្តជាប់ជាប្រចាំ នៅថ្នាក់កម្រងសាលារៀន តាមរូបភាពជាការប្រជុំបច្ចេកទេស ការបង្រៀនថ្នាក់និទស្សន៍ ថ្នាក់បង្ហាញ ការធ្វើទស្សនកិច្ចសិក្សា និងការបំប៉នសមត្ថភាព |
| សកម្មភាព | ជ្រើសរើសនិងចាត់តាំងគ្រូបង្រៀនល្អនៅតាមកម្រងសាលារៀន ធ្វើជាទីប្រឹក្សាគរុកោសល្យជំនាញ និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន |

# ១.៦. យុទ្ធសាស្ត្រនៃការអនុវត្ត រយៈពេលវែង

| យុទ្ធសាស្ត្រ៤ | ការពង្រឹងនិងពង្រីកកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង នៅទូទាំងប្រទេស |
| --- | --- |
| សកម្មភាព | ពង្រឹងការធ្វើអធិការកិច្ចនិងការពិនិត្យតាមដានពីថ្នាក់ក្រសួង មន្ទីរ អ.យ.ក.រាជធានី ខេត្ត គ្រូឧទ្ទេស សាលាគរុកោសល្យ ការិយាល័យ អ.យ.ក.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| សកម្មភាព | រៀបចំសិក្ខាសាលាបូកសរុបលទ្ធផលនិងចែករំលែកបទពិសោធនៃការផ្តល់ប្រឹក្សាគរុកោសល្យនៅកម្រិតក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងថ្នាក់ជាតិ |
| សកម្មភាព | ជំរុញឱ្យបង្កើតសហគមន៍អ្នកសិក្សាវិជ្ជាជីវៈ (PLC) រៀបចំការស្រាវជ្រាវប្រតិបត្តិ (Action Research) និងលើកទឹកចិត្តឱ្យមានការពិភាក្សាផ្លាស់ប្តូរយោបល់ដោយផ្ទាល់ ឬ ប្រព័ន្ធអនឡាញ ព្រមទាំងរក្សាទុករាល់ឯកសារដែលពាក់ព័ន្ធ |
| សកម្មភាព | ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រឹក្សាគរុកោសល្យកម្រិតថ្នាក់ដំបូង |
| សកម្មភាព | ពង្រឹងការធ្វើអធិការកិច្ចនិងការពិនិត្យតាមដានពីថ្នាក់ក្រសួង មន្ទីរ អ.យ.ក.រាជធានី ខេត្ត គ្រូឧទ្ទេស សាលាគរុកោសល្យ ការិយាល័យ អ.យ.ក.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ |

## ១.៦. យុទ្ធសាស្ត្រនៃការអនុវត្ត រយៈពេលវែង

| យុទ្ធសាស្ត្រ៤ | ការពង្រឹងនិងពង្រីកកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង នៅទូទាំងប្រទេស |
|---|---|
| សកម្មភាព | បន្តជំរុញដំណើរការបណ្ណាល័យ និងលើកកម្ពស់កម្រិតបណ្ណាល័យ( ជាបណ្ណាល័យសតវត្សទី២១ ឬ បណ្ណាល័យឌីជីថល សម្រាប់សាលារៀនដែលមានបណ្ណាល័យស្រាប់ និងបង្កើតបណ្ណាល័យថ្មី នៅតាមសាលារៀនដែលមិនទាន់មាន |
| សកម្មភាព | ជំរុញនិងលើកកម្ពស់សកម្មភាពអំណានឮ អំណានដៃគូ អំណានចូលរួម និងអំណានបុគ្គល តាមរយៈការសម្របសម្រួលពីគ្រូបង្រៀន និងក្រុមប្រឹក្សាកុមារ |
| សកម្មភាព | លើកទឹកចិត្តមាតាបិតា អ្នកអាណាព្យាបាលឱ្យ ខ្ចី-សង សៀវភៅពីបណ្ណាល័យ និង/ឬ ទិញសៀវភៅអានផ្សេងៗឱ្យកូនអាន ព្រមទាំងចូលរួមអានសៀវភៅជាមួយកូន ឬ ស្តាប់កូនអាននៅផ្ទះ |
| សកម្មភាព | លើកទឹកចិត្តឱ្យមានការបង្កើតនិងដំណើរការបណ្ណាល័យសហគមន៍ និងចូលរួមឧបត្ថម្ភ បរិច្ចាគសៀវភៅ និងឯកសារស្រាវជ្រាវផ្សេងៗ ពីសហគមន៍ សប្បុរសជន សិស្សានុសិស្ស អង្គការដៃគូ វិស័យឯកជន... |
| សកម្មភាព | រៀបចំឱ្យមានការប្រឡងប្រណាំងអំណាន និងគណិតវិទ្យានៅកម្រិតសាលារៀន កម្រងសាលារៀន និងក្រុងស្រុក ខណ្ឌ |

# ២. ផែនទី និងតម្រូវការថវិកា

SCALE UP TOOL FINAL for DEMO.xlsx

# ៣. សំណើសុំពិនិត្យនិងពិភាក្សាលើអត្រាឧបត្ថម្ភសម្រាប់ ដំណើរការវគ្គបំប៉ននៅកម្រិតកម្រងសាលារៀន

# ៣.១. អត្រាឧបត្ថម្ភកន្លងមករបស់អង្គភាពដែលពាក់ព័ន្ធ

| ចម្ងាយផ្លូវ | ប្រាក់ឧបត្ថម្ភ |
|---|---|
| ក្រោម ៥គ.ម. | មិនមានប្រាក់ឧបត្ថម្ភ |
| ចាប់ពី ៥ ដល់ ក្រោម ២០ គ.ម. | ប្រាក់ឧបត្ថម្ភ ៤ដុល្លារ/ថ្ងៃ |
| ចាប់ពី ២០ ដល់ ក្រោម ៤០ គ.ម. | ប្រាក់ឧបត្ថម្ភ ១៤ដុល្លារ/ថ្ងៃ និងសោហ៊ុយធ្វើដំណើរ ៤ដុល្លារ/ថ្ងៃ |
| ចាប់ពី ៤០ គ.ម. ឡើងទៅ | ប្រាក់ឧបត្ថម្ភ ៣៤ដុល្លារ/យប់ និង(១៤ដុល្លារ/ថ្ងៃត្រឡប់វិញ) រួមបញ្ចូលទាំងសោហ៊ុយធ្វើដំណើរ ៨ដុល្លារ/វគ្គ |

# ៣.២. សំណើសុំអត្រាឧបត្ថម្ភថ្មី

| ចម្ងាយផ្លូវ | ប្រាក់ឧបត្ថម្ភ |
|---|---|
| ក្រោម ២០គ.ម. | ប្រាក់ឧបត្ថម្ភ ៦ដុល្លារ/ថ្ងៃ |
| ចាប់ពី ២០ ដល់ ក្រោម ៤០ គ.ម. | ប្រាក់ឧបត្ថម្ភ ១៤ដុល្លារ/ថ្ងៃ និងសោហ៊ុយធ្វើដំណើរ ៤ដុល្លារ/ថ្ងៃ |
| ចាប់ពី ៤០ គ.ម. ឡើងទៅ | ប្រាក់ឧបត្ថម្ភ ៣៤ដុល្លារ/យប់ និង(១៤ដុល្លារ/ថ្ងៃត្រឡប់វិញ) រួមបញ្ចូលទាំងសោហ៊ុយធ្វើដំណើរ ៨ដុល្លារ/វគ្គ |

សូមអរគុណ

ចំពោះការយកចិត្តទុកដាក់ស្ដាប់!

